# ច្បាប់សំរាប់គ្រឿងឲ្យសញ្ញាពេលមានផ្សែងនៅរដ្ឋ NSW

Fact Sheet 11A – Community Risk Management. Revised 25/11/2005 - Khmer

- **NSW FIRE BRIGADES**
- **ACT FIRE BRIGADE**
- **NSW RURAL FIRE SERVICE**
- **ACT RURAL FIRE SERVICE**

## ហេតុការណ៍

នៅថ្ងៃទី១ ខែឧសភា ឆ្នាំ២០០៦ អ្នករស់នៅក្នុងរដ្ឋ NSW ត្រូវតែដាក់គ្រឿងឲ្យសញ្ញាពេលមានផ្សែង (Smoke Alarm) យ៉ាងតិចមួយគ្រឿងនៅក្នុងផ្ទះរបស់គេ ។ នេះគិតបញ្ចូលទាំងផ្ទះសំរាប់ជួល ផ្ទះដែលម្ចាស់ផ្ទះនៅ ហើយនិងកន្លែងស្នាក់នៅបណ្តោះអាសន្ន ។

## គោលជំហរនៃក្រសួងរំលត់ភ្លើងរដ្ឋ NSW ចំពោះ (Smoke Alarm) គឺ:

- ☐ Smoke Alarm ទាំងអស់ដែលដាក់នៅក្នុងកន្លែងស្នាក់នៅទូទាំងរដ្ឋ NSW ត្រូវស្របតាមខ្នាត **AS3786** ឬ **AS 12239**
- ☐ Smoke Alarm ត្រូវដាក់ឲ្យស្របទៅតាមសេចក្តីណែនាំរបស់ក្រុមហ៊ុនដែលផលិត ហើយនិងដាក់តាមកន្លែងដែលស្របទៅតាមខ្នាតសំណង់អូស្ត្រាលី (Building Code of Australia) និងសេចក្តីណែនាំរបស់ក្រុមហ៊ុនដែលផលិត ។
- ☐ គេចូលចិត្ត Hard-wired smoke alarm ជាង ព្រោះថា Smoke Alarm នេះប្រើតែថ្មកម្លាំង ៩ វ៉ូលត៍ មួយដុំដែលផ្តល់ការការពារ ប្រសិនបើគេដាក់វាឲ្យបានត្រឹមត្រូវហើយនិងដូរវាជារឿយៗផង ។
- ☐ នៅលំនៅមួយ (Class 1 buildings) គេដាក់ Smoke Alarm នៅខាងក្រៅកន្លែងសំរានទាំងអស់ ហើយនិងនៅតាមផ្លូវដើរត្រង់ចន្លោះកន្លែងសំរាន និង ច្រកចេញទៅខាងក្រៅ ។
- ☐ នៅក្នុងអាគារដែលមានលំនៅ ២ ឬច្រើនដាច់ពីគ្នា ដូចជា ផ្ទះយូនិត គេដាក់ Smoke Alarm នៅខាងក្រៅកន្លែងសំរានទាំងអស់ ហើយនិងនៅតាមផ្លូវដើរទាំងអស់ត្រង់ចន្លោះកន្លែងសំរាន និង ច្រកចេញទៅផ្លូវរួម (Common Corridor) ។
- ☐ នៅក្នុងលំនៅច្រើនជាន់ បន្ថែមលើខដែលបានចែងខាងលើនេះ គេដាក់ Smoke Alarm នៅតាមផ្លូវដើរត្រង់ចន្លោះជាន់និមួយៗ ។
- ☐ ធ្វើឲ្យប្រាកដថា ដាក់ Smoke Alarm ឲ្យឆ្ងាយពីម៉ាស៊ិនត្រជាក់ គ្រឿងដុតកំដៅ ដង្ហាល់និងគ្រឿងកម្រិតសីតុណ្ហភាព (temperature control devices) ដើម្បីចៀសវាងកុំឲ្យខ្យល់ចេញពីគ្រឿងទាំងនេះអាចប៉ះពាល់ Smoke Alarm ។
- ☐ ក្នុងកាលៈទេសៈដែលធ្វើទៅបាន ម្ចាស់ផ្ទះឬអ្នកជួលផ្ទះ ដាក់ Smoke Alarm ទាំងពីរមុខគឺ photo-electric និង ionisation smoke alarms ។
- ☐ ការទទួលខុសត្រូវលើការដាក់គ្រឿងនេះ គឺឋិតនៅលើម្ចាស់សំណង់ ឬម្ចាស់ផ្ទះ ក្នុងករណីយកន្លែងស្នាក់នៅជាកន្លែងជួល ។
- ☐ Smoke Alarm ដែលប្រើអគ្គិសនី ២៤០ វ៉ូលត៍ ត្រូវដាក់ដោយអ្នកមានជំនាញខាងអគ្គិសនី ហើយ Smoke Alarm ដែលប្រើថ្ម ៩ វ៉ូលត៍អាចដាក់បានដោយអ្នកមានសមត្ថភាពដែលមិនមែនជាអ្នកមានជំនាញខាងអគ្គិសនី ។
- ☐ ចំពោះកន្លែងស្នាក់នៅបណ្តោះអាសន្នដែលពិបាករកអគ្គិសនីកម្លាំង ២៤០ វ៉ូលត៍ ឬក៏គ្មាន (ដូចជា តង់ ទូក ការ៉ាវ៉ានជាដើម) គេត្រូវប្រើ Smoke Alarm ដែលប្រើថ្ម ។
- ☐ តាមកន្លែងស្នាក់នៅបណ្តោះអាសន្ន Smoke Alarm ត្រូវតែដាក់នៅគ្រប់កន្លែងសំរាន ។
- ☐ ច្បាប់ផ្តល់សិទ្ធិឲ្យម្ចាស់ផ្ទះ ឬភ្នាក់ងាររបស់ម្ចាស់ផ្ទះចូលទៅក្នុងបរិវេណផ្ទះបាន ដើម្បីដាក់ Smoke Alarm ឲ្យតែគេផ្តល់ដំណឹងនេះដល់អ្នកជួលផ្ទះដឹងមុន ២ថ្ងៃយ៉ាងតិច ។
- ☐ ម្ចាស់ផ្ទះត្រូវទទួលខុសត្រូវលើការផ្តល់ Smoke Alarm និងថ្មវា ហើយនិងការដាក់វាផងដែរ ។
- ☐ អ្នកជួលផ្ទះត្រូវទទួលខុសត្រូវលើការថែទាំ Smoke Alarm ។ នេះគិតទាំងការធ្វើតេស្ត ហើយនិងការជូតសំអាតផង ។

**ចំពោះពត៌មានថែមទៀត សូមទាក់ទងស្ថានីយ៍រំលត់ភ្លើង ឬមជ្ឈមណ្ឌលត្រួតត្រាភ្លើងតាមតំបន់លោកអ្នក**

**ឬបើកមើល: www.fire.nsw.gov.au www.rfs.nsw.gov.au**

**នៅពេលអាសន្ន សូមទូរស័ព្ទលេខ 000**